សេចក្តីប្រកាសព័ត៌មាន

# សហភាពអឺរ៉ុប និងយូនីសេហ្វ ៖ កសាងភាពធន់របស់សហគមន៍ចំពោះគ្រោះទឹកជំនន់នៅក្នុងប្រទេសកម្ពុជា

*សហភាពអឺរ៉ុបផ្តល់ថវិកាចំនួន ៦០ម៉ឺន អឺរ៉ូ ដល់គម្រោងត្រៀមបង្ការចំពោះគ្រោះទឹកជំនន់ ដែលតែងកើតមានជាបន្តបន្ទាប់ និងដើម្បីកាត់បន្ថយហានិភ័យសុខភាពកុមារកម្ពុជា និងគ្រួសាររបស់ពួកគេ។*

**ភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤៖** នាយកដ្ឋានជំនួយមនុស្សធម៌ និងការពារជនស៊ីវិល (ECHO) របស់សហភាពអឺរ៉ុប នឹងផ្តល់ទឹកប្រាក់ចំនួន ៦០*ម៉ឺន អឺរ៉ូ* (ប្រមាណជា ៨៣.២000 ដុល្លារអាមេរិក) ដើម្បីជួយកាត់បន្ថយហានិភ័យនៃជំងឺឆ្លងតាមរយៈទឹកកខ្វក់ ដែលកើតឡើងលើកុមារកម្ពុជាដែលងាយរងគ្រោះ និងគ្រួសាររបស់ពួកគេ នៅអំឡុងពេល និងក្រោយពេលគ្រោះទឹកជំនន់។

គ្រោះទឹកជំនន់ដែលកើតមានជាបន្តបន្ទាប់ និងជារៀងរាល់ឆ្នាំនៅក្នុងប្រទេសកម្ពុជា បង្កឱ្យមានផលប៉ះពាល់ដល់ខេត្តចំនួន១៩ លើខេត្តទាំង២៥ នៃប្រទេស។ នៅក្នុងឆ្នាំ ២០១៣ គ្រោះទឹកជំនន់បានប៉ះពាល់ដល់ប្រជាពលរដ្ឋកម្ពុជា យ៉ាងហោចណាស់ចំនួន ១,៥ លាននាក់ ដែលក្នុងនោះរួមមានការបាត់បង់ជីវិត ការខូចខាតហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ (រួមមានអណ្តូងទឹកបរិភោគប្រមាណ ១២000 កន្លែង) និងការបំផ្លិចបំផ្លាញផលដំណាំ និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ។

មូលនិធិរបស់សហភាពអឺរ៉ុបនេះ នឹងផ្តល់លទ្ធភាពដល់អង្គការយូនីសេហ្វ ក្នុងការជួយពង្រឹងលទ្ធភាពត្រៀមបង្ការ និងកសាងនូវភាពធន់របស់សហគមន៍ នៅតាមតំបន់ងាយរងគ្រោះដោយសារទឹកជំនន់ តាមរយៈការបន្សុទ្ធទឹកដោយប្រើប្រាស់សារធាតុក្លរីន និងការស្តារអណ្តូងនៅក្នុងឃុំចំនួន ៥0។ ដើម្បីធានាឱ្យមានការអនុវត្តសកម្មភាពទាំងនេះឱ្យបានគ្រប់គ្រាន់ គម្រោងនឹងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ក្រោមជាតិចំនួន ១00 នាក់ មកពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន៥ និងការិយាល័យស្រុកចំនួន ១៨ ដែលស្ថិតក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ។

លោកស្រី Rana Flowers តំណាងអង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា “ថវិការបស់សហភាពអឺរ៉ុបនេះ នឹងផ្តល់លទ្ធភាពឱ្យយូនីសេហ្វ រៀបចំសកម្មភាពកម្រិតស្ថាប័នក្នុងការសម្អាតអណ្តូងឲ្យបានត្រឹមត្រូវក្រោយពេលគ្រោះទឹកជំនន់ និងកាន់តែសំខាន់ជាងនេះទៅទៀតគឺធ្វើការកែសម្រួលគម្របអណ្តូងនិងលើកផ្ទៃជុំវិញអណ្តូងឲ្យខ្ពស់និងជិតល្អជាងមុន ដើម្បីកុំឱ្យទឹកជំនន់អាចជ្រាបចូលអណ្តូងបាន។ ការធ្វើបែបនេះនឹងជួយធ្វើឱ្យមានភាពខុសប្លែកគ្នាយ៉ាងធំធេង នៅក្នុងការកាត់បន្ថយហានិភ័យ ដែលអាចកើតមានចំពោះកុមារ នៅក្នុងពេលដែលមានគ្រោះទឹកជំនន់កើតឡើង។”

គម្រោងក៏នឹងបណ្តុះបណ្តាលមន្ត្រីថ្នាក់ភូមិចំនួន ៥០០នាក់ អំពីរបៀបលើកកម្ពស់អនាម័យមូលដ្ឋាន ដើម្បីអប់រំដល់ប្រជាពលរដ្ឋតាមគ្រួសារឲ្យយល់ដឹងពីសារៈសំខាន់នៃអនាម័យ សម្រាប់បង្ការជំងឺនានា ដូចជាជំងឺរាករូសជាដើម។ នៅក្នុងប្រទេសកម្ពុជាមានកុមារប្រមាណ ២៣០០នាក់ បានស្លាប់ជារៀងរាល់ឆ្នាំ បង្កដោយជំងឺ ដែលគេអាចបង្ការបាន ដូចជាជំងឺរាករូសជាដើម។ ការបណ្តុះបណ្តាលនេះ នឹងមានដាក់បញ្ចូលការសាកល្បងប្រើប្រាស់បង្គន់បណ្តែតទឹកចល័តបែបធម្មជាតិ ដែលអាចស្តុកលាមកនិងទឹកនោម ប្រកបដោយអនាម័យនិងបំលែងទៅជាជីកំប៉ុស្តិ៍ក្នុងអំឡុងពេលមានគ្រោះទឹកជំនន់ហើយដែលក្រោយមកគេអាចយកមកវាមកប្រើជាជីកសិកម្មប្រកបដោយសុវត្ថិភាព។

លោក Bernard Jaspers Faijer អ្នកគ្រប់គ្រងកម្មវិធីរបស់ ECHO ប្រចាំប្រទេសកម្ពុជាបានមានប្រសាសន៍ថា “សហភាពអឺរ៉ុបធ្វើសកម្មភាព នៅពេលមានតម្រូវការជំនួយសង្គ្រោះបន្ទាន់។ ប្រទេសកម្ពុជា ជាញឹកញាប់ទទួលរងផលប៉ះពាល់ពីគ្រោះមហន្តរាយទឹកជំនន់។ នៅពេលដែលតម្រូវការមនុស្សធម៌មានកម្រិតលើសពីសមត្ថភាពនៅមូលដ្ឋានដែលអាចផ្តល់បាន យើងបានត្រៀមខ្លួនរួចជាស្រេចដើម្បីជួយដល់អ្នកដែលរងផលប៉ះពាល់ ដោយសារគ្រោះមហន្តរាយនានា។ ការងាររបស់អង្គការយូនីសេហ្វ មានសារៈសំខាន់យ៉ាងធំធេង ក្នុងការគាំទ្រប្រជាពលរដ្ឋឱ្យចេះត្រៀមខ្លួនឲ្យបានកាន់តែប្រសើរជាងមុន ក្នុងការទប់ទល់នឹងគ្រោះទឹកជំនន់នាពេលអនាគត”។

មូលនិធិនេះ ក៏នឹងប្រើប្រាស់ផងដែរដើម្បីបណ្តុះបណ្តាលមន្ត្រីថ្នាក់ក្រោមជាតិ អំពីរបៀបប្រើប្រាស់ទូរស័ព្ទដៃប្រកបដោយភាពច្នៃប្រឌិត ដើម្បីបញ្ជូនព័ត៌មានអំពីការវាយតម្លៃការខូចខាតអណ្តូង ដែលរងផលប៉ះពាល់ដោយសារទឹកជំនន់ ទៅកាន់មូលដ្ឋានទិន្នន័យថ្នាក់ជាតិ ក្នុងអំឡុងនិងក្រោយពេលដែលមានគ្រោះអាសន្នកើតឡើង។ ព័ត៌មាននេះនឹងផ្តល់ឱ្យរដ្ឋាភិបាល អង្គការសហប្រជាជាតិ និងទីភ្នាក់ងារផ្តល់ជំនួយដទៃទៀត នូវព័ត៌មានសំខាន់ៗឲ្យបានទាន់ពេលវេលា ដូចជាព័ត៌មានអំពីគ្រួសារនិងតំបន់រងផលប៉ះពាល់ ដែលពុំមានទឹកស្អាតបរិភោគ ដើម្បីឲ្យស្ថាប័នទាំងនោះអាចចាត់វិធានការឆ្លើយតបជាបន្ទាន់បាន។ #####

### អំពីយូនីសេហ្វ

យូនីសេហ្វលើកកម្ពស់សិទ្ធិនិងសុខុមាលភាពរបស់កុមារគ្រប់រូប នៅក្នុងគ្រប់ការងារទាំងអស់របស់យើង។ រួមគ្នាជាមួយនឹងដៃគូរបស់យើង យើងធ្វើការងារនៅក្នុងប្រទេសនិងដែនដីចំនួន១៩០ ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តខាងលើឲ្យទៅជាសកម្មភាពអនុវត្តជាក់ស្តែង តាមរយៈការផ្តោតការយកចិត្តទុកដាក់ជាពិសេសដល់កុមារដែលងាយរងគ្រោះជាងគេ និងមិនត្រូវបានគេយកចិត្តទុកដាក់ ដើម្បីជាប្រយោជន៍ដល់កុមារគ្រប់រូបនៅគ្រប់ទិសទីទាំងអស់។ សម្រាប់ព័ត៌មានបន្ថែមអំពីយូនីសេហ្វនិងការងាររបស់អង្គការនេះនៅក្នុងប្រទេសកម្ពុជា សូមមើលគេហទំព័រ www.unicef.org.kh។

### អំពីនាយកដ្ឋានជំនួយមនុស្សធម៌ និង ការពារជនស៊ីវិល (ECHO) របស់គណៈកម្មការអឺរ៉ុប

នាយកដ្ឋានជំនួយមនុស្សធម៌ និងការពារជនស៊ីវិល (ECHO) របស់សហភាពអឺរ៉ុប ផ្តល់ថវិកាដល់សកម្មភាពមនុស្សធម៌ដល់រងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិនិងជម្លោះនានា។ ជំនួយនេះត្រូវបានផ្តល់ដោយមិនលម្អៀង ផ្តល់ផ្ទាល់ដល់ជនរងគ្រោះ ដោយមិនប្រកាន់ពូជសាសន៍ ក្រុមជនជាតិ សាសនា យេនឌ័រ អាយុ សញ្ជាតិ ឬនិន្នាការនយោបាយ។ ECHO គឺជាអ្នកផ្តល់ជំនួយមនុស្សធម៌ដ៏ធំមួយដល់អង្គការយូនីសេហ្វ។

### សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖

Denise Shepherd-Johnson ប្រធានផ្នែកប្រាស្រ័យទាក់ទងរបស់យូនីសេហ្វប្រចាំប្រទេសកម្ពុជា

ទូរស័ព្ទដៃ ៖ 092 555 294 ឬ អ៊ីម៉េល ៖ dshepherdjohnson@unicef.org